**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**ក្រសួងមហាផ្ទៃ**

*លេខ:* ✓

# សេចក្តីជូនដំណឹង
# ស្តីពី
# ការបង្កើត ការចុះបញ្ជី និងការធ្វើសកម្មភាព
# របស់គណបក្សនយោបាយ

អនុលោមតាមរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ត្រង់មាត្រា៤២ បានចែងថា " ប្រជាពលរដ្ឋខ្មែរមានសិទ្ធិបង្កើតសមាគម និងគណបក្សនយោបាយ។ សិទ្ធិនេះត្រូវកំណត់ក្នុងច្បាប់ "។ ផ្អែកតាមបទប្បញ្ញត្តិដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីគណបក្សនយោបាយត្រូវបានរៀបចំបង្កើតឡើង និងបានប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ក្នុងគោលបំណងធានាដល់ការបង្រួបបង្រួមជាតិ ពង្រឹងឯកភាពជាតិ ដោយផ្អែកលើគោលការណ៍លិទ្ធិប្រជាធិបតេយ្យ សេរីពហុបក្សធានាការគោរពសិទ្ធិមនុស្ស និងការគោរពច្បាប់ បន្ទាប់ពីប្រទេសកម្ពុជាបានឆ្លងកាត់ទុក្ខសោកវិនាសកម្មជាងបីទសវត្សរ៍កន្លងមក។

រហូតមកដល់ពេលបច្ចុប្បន្ននេះ កម្ពុជាយើងមានគណបក្សនយោបាយសរុបចំនួន៦៧ ដែលក្នុងនោះគណបក្សចំនួន៤៤ បានចុះបញ្ជីនៅក្រសួងមហាផ្ទៃ ហើយចំនួន២៣ ទៀតពុំទាន់បានចុះបញ្ជីនៅឡើយ។ ដើម្បីធានាបាននូវការធ្វើសកម្មភាពស្របតាមបទប្បញ្ញត្តិ នៃច្បាប់ ក្រសួងមហាផ្ទៃ មានកិត្តិយសសូមជម្រាបជូនដល់គ្រប់តំណាងស្ថាបនិកគណបក្សនយោបាយ ដែលបានសុំបង្កើតនៅក្រសួងមហាផ្ទៃរួចហើយ ក៏ដូចជាសាធារណមតិជាតិ អន្តរជាតិ មេត្តាជ្រាបថា៖

១.កន្លងមកក្រសួងមហាផ្ទៃបានពិនិត្យឃើញថា គណបក្សនយោបាយមួយចំនួនដែលបានសុំបង្កើតស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧ បាននិងកំពុងធ្វើសកម្មភាព ដោយពុំទាន់បានចុះបញ្ជី និងទទួលបានសុពលភាពស្របតាមការកំណត់ដូចមានចែងក្នុងជំពូកទី៥ នៃច្បាប់នេះនៅឡើយ។

២. ក្រសួងមហាផ្ទៃ សូមបញ្ជាក់ថា ផ្អែកតាមបទប្បញ្ញត្តិក្នុងមាត្រា៩ ត្រង់វាក្យខណ្ឌទី២ ជំពូកទី២ នៃច្បាប់ស្តីពីគណបក្សនយោបាយ បានចែងថា " គណបក្សនយោបាយដែលទើបផ្តើមបង្កើត ត្រូវធ្វើការបោះឆ្នោតជ្រើសតាំងគណៈកម្មាធិការបណ្តោះអាសន្ន ដែលមានសមាជិកយ៉ាងតិច ៧រូប ហើយដែលម្នាក់ៗ មានអាយុយ៉ាងតិច ២៥ឆ្នាំ សម្រាប់រៀបចំបែបបទនិងបំពេញលក្ខខណ្ឌនៃការសុំចុះបញ្ជីគណបក្សនយោបាយ តាមការកំណត់ដូចមានចែងក្នុងជំពូកទី៥ នៃច្បាប់នេះ ដើម្បីទទួលសុពលភាព "។

៣. ដើម្បីមានសិទ្ធិចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលនឹងប្រព្រឹត្តទៅនៅក្នុងឆ្នាំ២០១៧ និងឆ្នាំ២០១៨ ខាងមុខនេះ ក្រសួងមហាផ្ទៃ សូមអំពាវនាវដល់តំណាងស្ថាបនិកគ្រប់គណបក្សនយោបាយ ដែលបានសុំបង្កើតរួចហើយ និងមានបំណងធ្វើសកម្មភាព ត្រូវរួសរាន់បំពេញបែបបទ និងលក្ខខណ្ឌ ដូចមានចែងក្នុងជំពូកទី៥ ត្រង់មាត្រា២០ នៃច្បាប់ស្តីពីគណបក្សនយោបាយ តាមខ្លឹមសារដូចខាងក្រោម៖

១.- ពាក្យសុំចុះបញ្ជីគណបក្សនយោបាយ ត្រូវមានហត្ថលេខារបស់ប្រធានគណបក្សនយោបាយ

២.- ឈ្មោះជាអក្សរពេញនិងអក្សរកាត់ និងសញ្ញាសម្គាល់របស់គណបក្សនយោបាយ

៣.- អាសយដ្ឋាននៃទីស្នាក់ការកណ្ដាល របស់គណបក្សនយោបាយ

៤.- ច្បាប់ដើមនៃលក្ខន្តិកៈគណបក្សនយោបាយ ចំនួនពីរច្បាប់

៥.- បទបញ្ជាផ្ទៃក្នុងរបស់គណបក្សនយោបាយ ប្រសិនបើមាន

៦.- គោលនយោបាយ និងកម្មវិធីនយោបាយសំខាន់ៗ របស់គណបក្សនយោបាយ

៧.- សេចក្ដីថ្លែងការណ៍ជាលាយលក្ខណ៍អក្សររបស់គណបក្សនយោបាយស្ដីពីការគោរពរដ្ឋធម្មនុញ្ញ ច្បាប់ស្ដីពីគណបក្សនយោបាយ និងបទប្បញ្ញត្តិផ្សេងៗជាធរមាន និងគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និងការគោរពសិទ្ធិមនុស្ស

៧.- បញ្ជីឈ្មោះដោយមានអាយុ អាសយដ្ឋាន និងស្នាមមេដៃរបស់សមាជិកទាំង៤ ០០០នាក់ ដោយមានបញ្ជាក់លេខប័ណ្ណសមាជិកគណបក្ស និងកាលបរិច្ឆេទនៃការចូលជាសមាជិកភាពគណបក្សនយោបាយ

៩.- ជីវប្រវត្តិសង្ខេបរបស់ប្រធានឬសមាជិកស្ថាបនិកចំនួន ៣នាក់យ៉ាងតិច ក្នុងម្នាក់ចំនួនមួយច្បាប់ដោយមានបិទរូបថតទំហំ ៤គុណនឹង៦

១០.- សេចក្ដីប្រកាសអំពីគណនីធនាគារ នៅធនាគារក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបានការទទួលស្គាល់ពីធនាគារជាតិ នៃកម្ពុជា

១១.- បង្កាន់ដៃថ្លៃអាករ ចុះបញ្ជីគណបក្សនយោបាយមួយច្បាប់។ ថ្លៃអាករនេះត្រូវកំណត់ដោយប្រកាសអន្តរក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

៤. ក្នុងគោលបំណងធានានូវការអនុវត្តច្បាប់ស្ដីពីគណបក្សនយោបាយ ក្រសួងមហាផ្ទៃសូមស្នើដល់គ្រប់គណបក្សនយោបាយដែលបានបង្កើតរួចហើយ តែពុំទាន់បានចុះបញ្ជីដើម្បីទទួលបានសុពលភាព ហើយមានបំណងធ្វើសកម្មភាពណាមួយ ឬលើកស្លាកសញ្ញាទីស្នាក់ការសាខានៅរាជធានីភ្នំពេញ និងទីស្នាក់ការសាខាគ្រប់ខេត្ត តំណាងស្ថាបនិកនៃគណបក្សនយោបាយ ត្រូវធ្វើលិខិតជាលាយលក្ខណ៍អក្សរស្នើសុំការអនុញ្ញាតជាមុនពីក្រសួងមហាផ្ទៃ។

៥. គ្រប់គណបក្សនយោបាយត្រូវធ្វើសកម្មភាពឲ្យស្របតាមគោលការណ៍ច្បាប់ និងរាល់លិខិតបទដ្ឋានគតិយុត្តនានា ដើម្បីបំពេញបេសកកម្មរបស់ខ្លួនប្រកបដោយគណនេយ្យភាព តម្លាភាព និងអព្យាក្រឹតភាព ក្នុងគោលបំណងពង្រឹងនីតិរដ្ឋនៅកម្ពុជាឲ្យកាន់តែរឹងមាំ ស្របតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។

រាជធានីភ្នំពេញ.ថ្ងៃទី      ខែកក្កដា ឆ្នាំ២០១៦

ព្រះរាជាណាចក្រកម្ពុជា
ក្រសួងមហាផ្ទៃ